# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៤៨ ស្តីពី ការតែងតាំងឯកឧត្តម អ៊ី ឈាន ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៦៣៥៥

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៤៩ ស្តីពី ការតែងតាំងឯកឧត្តម ខាន់ ម៉ា ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៦៣៥៦

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥០ ស្តីពី ការដាក់ឯកឧត្តម ពេជ ឌុន ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងធនធានទឹក និងឧតុនិយម ៦៣៥៧

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥១ ស្តីពី ការដាក់មន្ត្រីរាជការ ០២ រូប ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ ៦៣៥៨

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី តាមលំដាប់ថ្នាក់ ចំពោះ អស់លោក ជាកងកម្លាំងប្រដាប់អាវុធបរទេស ចំនួន ០៥ រូប ៦៣៥៩

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៣ ស្តីពី ការតែងតាំងឯកឧត្តម អ៊ុំ សាខ ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ៦៣៦០

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៤ ស្តីពី ការតែងតាំងឯកឧត្តម ជា ថោយ ជាអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ៦៣៦១

១៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី ហ៊ី ព្រូ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦៣៦២

| | | |
|---|---|---|
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ដួង ខៀម** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៦៣៦៣ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជូនឯកឧត្តម **តែ ណារុទ្ធ** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៥ ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ៦៣៦៤ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនសពលោកស្រីវរសេនីយ៍ឯក **ប្រាក់ សៅនី** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៦៣៦៥ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៥៩ ស្តីពី ការផ្ទេរបញ្ចូល និងតែងតាំងឋានន្តរស័ក្តិលោក **អេង គីមហៃ** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខ័ណ្ឌមន្ត្រី រដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី នាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ៦៣៦៦ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦០ ស្តីពី ការតែងតាំងលោក **ហេង ប៊ុច** និងលោក **ហួង ចាន់សុខា** ជា ឧកញ៉ា | ៦៣៦៧ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦១ ស្តីពី ការដាក់ឯកឧត្តម **គឹម សយសាម៉ាឡូន** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងផែនការ | ៦៣៦៨ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦២ ស្តីពី ការតែងតាំងឯកឧត្តម **រស់ ចាន់សន** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ៦៣៦៩ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក TRAN VIET HUNG | ៦៣៧០ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ឯកឧត្តម និងអស់លោក ចំនួន ០៥ អង្គ/រូប | ៦៣៧១ |
| ១៤-៦-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៧៦៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ១១ រូប | ៦៣៧២ |

# គ

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


០៩-៧-២០១៤ -អនុក្រឹត្យលេខ ២១១ អនក្រ.បក ស្តីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ៦៣៧៤

***សេចក្តីកែតម្រូវ :** *ដោយមានកំហុសក្នុងការចុះផ្សាយអនុក្រឹត្យលេខ ២៥៥ អនក្រ.តត នៅក្នុងរាជកិច្ចលេខ ២៥ សប្តាហ៍ទី ១ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៤ ទំព័រ ២៩៨២ ដូច្នេះយើងខ្ញុំសូមចុះផ្សាយអនុក្រឹត្យនេះ ក្នុងរាជកិច្ច លេខ ៥៣ ម្តងទៀត។ សូមអរគុណ !*

១១-៣-២០១៤ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច តែងតាំងមុខតំណែងមន្ត្រីរាជការ និងនាយនគរបាលជាតិ ៦៣៩៣

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៧៧ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបវេល នៃខេត្តបាត់ដំបង ៦៣៩៥

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៧៨ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកឯកភ្នំ នៃខេត្តបាត់ដំបង ៦៣៩៧

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៧៩ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកមោងឫស្សី នៃខេត្តបាត់ដំបង ៦៣៩៩

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨០ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុករុក្ខគីរី នៃខេត្តបាត់ដំបង ៦៤០១

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨១ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុករតនមណ្ឌល នៃខេត្តបាត់ដំបង ៦៤០៣

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨២ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកសង្កែ នៃខេត្តបាត់ដំបង ៦៤០៥

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៣ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកសំឡូត នៃខេត្តបាត់ដំបង ៦៤០៧

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៤ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកសំពៅលូន នៃខេត្តបាត់ដំបង ៦៤០៩

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៥ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកភ្នំព្រឹក នៃខេត្តបាត់ដំបង ៦៤១១

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៦ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកំរៀង នៃខេត្តបាត់ដំបង ៦៤១៣

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៧ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកគាស់ក្រឡ នៃខេត្តបាត់ដំបង ៦៤១៥

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៨ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកជើងព្រៃ នៃខេត្តកំពង់ចាម ៦៤១៧

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៨៩ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងកំពង់ចាម នៃខេត្តកំពង់ចាម ៦៤១៩

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩០ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្ទឹងត្រង់ នៃខេត្តកំពង់ចាម ៦៤២១

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩១ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកកោះសូទិន នៃខេត្តកំពង់ចាម ៦៤២៣

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩២ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្រីសន្ធរ នៃខេត្តកំពង់ចាម ៦៤២៥

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបាធាយ នៃខេត្តកំពង់ចាម ៦៤២៧

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩៤ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកចំការលើ នៃខេត្តកំពង់ចាម ៦៤២៩

២៩-៥-២០១៤ -អនុក្រឹត្យលេខ ៦៩៥ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកព្រៃឈរ នៃខេត្តកំពង់ចាម ៦៤៣១

## ២.សេចក្តីសម្រេច

១០-៧ ២០១៤ -សេចក្តីសម្រេចលេខ ១១៦ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ ៦៤៣៣

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

០២-៦-២០១៤ -ប្រកាសលេខ ១២៥ បទ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ៦៤៣៦

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

២៨-៥-២០១៤ -ប្រកាសលេខ ៤៥៣ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូ អិលធីឌី បង្កើតរោងចក្រផលិត ប្រេងកាត ៦៤៦០

០៦-៦-២០១៤ -ប្រកាសលេខ ៤៧០ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ហុងយ៉ាង ហ្វើនីឈ័រ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រផលិត គ្រឿងសង្ហារឹម ៦៤៦៤

០៦-៦-២០១៤ -ប្រកាសលេខ ៤៧១ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន យ៉ូ មី ហុង ហៅហ្វូល ប្រដាក់ បង្កើតរោងចក្រផលិត កម្រាលព្រំ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ៦៤៦៨

០៩-៦-២០១៤ -ប្រកាសលេខ ៤៨៣ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូត្រាក់ ខូ អិលធីឌី បង្កើតរោងចក្រផលិត ឧបករណ៍ដឹកជញ្ជូនឥវ៉ាន់ប្រើដៃរុញ ៦៤៧២

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោរាស ភូមជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **អ៊ី ឈាន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៧.១៤០៦.៧៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៦៧ ស.ណ
សំណៅចម្លងតាមច្បាប់ដើម សំរាប់ជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង ឯកឧត្តម **ខាន់ ម៉ា** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

លេខ:៧៧៧ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ឯកឧត្តម ពេជ ឌុន ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងធនធានទឹក និងឧតុនិយម ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៤ តទៅ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ករ. ១៤០៦. ៧៥៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៧៥០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥១

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់មន្ត្រីរាជការ ០២ រូប ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ :

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃ-ខែ-ឆ្នាំចូលនិវត្តន៍ |
|---|---|---|---|
| ១ | ឯកឧត្តម **ប៊ុក ម៉ាន់នី** | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១-១០-២០១៤ |
| ២ | ឯកឧត្តម **កែន សុផល** | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០១-១១-២០១៤ |

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥៧.១៤០៦.៧៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៥៣ ស.ណ
**សំណៅដែលមានអង្គជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

ក-គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍**

- ឧត្តមសេនីយ៍ទោ NGUYEN PHUONG NAM

ខ-គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

១- ឧត្តមសេនីយ៍ត្រី NGUYEN HOANG THUY

២- ឧត្តមសេនីយ៍ត្រី PHAN HOANG THU

៣- ឧត្តមសេនីយ៍ត្រី TRUONG VAN THANH

៤- វរសេនីយ៍ឯក NGUYEN THANH HAI

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧. ១៤០៦. ៧៦៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៤៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តែងតាំង ឯកឧត្តម **អ៊ុច លាង** ជាទីប្រឹក្សា ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្ស ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

[illegible]

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៥៥ ស.ណ
**សំណៅដែលមានតម្លៃជាការចេញផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ខា ថៅឃ ជាអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧.៤០៦.៧៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៥៩ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ហ៊ី ព្រូ** អត្តលេខ ០៦៨៨ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៤០៦.៧៦៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៧៦៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋាននន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ដួង ចៀម** អត្តលេខ ០៥៥៣ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]: ១៤០៦.៧៧០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៧៦៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្ដីពីការកែសម្រួលនិងការធ្វើនិយ័តភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ ជូនឯកឧត្ដម **តែ ណាវុធ** ពីឋានន្តរស័ក្តិរដ្ឋមន្ត្រី ថ្នាក់លេខ ៥ ទៅឋានន្តរស័ក្តិឧត្ដមមន្ត្រី ថ្នាក់ពិសេស ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៧. ១៤០៦. ៧៧២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤*

លេខៈ ៧៥១ ស.ណ
**សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនសពលោកស្រីវរសេនីយ៍ឯក **ប្រាក់ សៅនី** អត្តលេខ ០៩០២៤ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣៧. ១៤០៦. ៧៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៧៧១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៥៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ទេរបញ្ចូល និងតែងតាំងឋានន្តរស័ក្តិ លោក **សេង គឹមហៃ** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៧៣៥៨៦ ដោយឥតបៀវត្សថ្នាក់ឧត្តមសេនីយ៍ ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥៧.១៤០៦.៧៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៧៧៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៦០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

តែងតាំង :

១- លោក ហេង ម៉ិច

២- លោក ហួង ចាន់សុខា

ជា

**ឧកញ៉ា**

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៧៧. ១៤០៦. ៧៧៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤*

លេខ: ៧៧៦ ស.ណ
សំណៅចំលងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ីយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ឯកឧត្តម **គឹម សយសាម៉ាឡែន** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងផែនការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧-១៤០៦-៧៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ ៧៥៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **រស់ ចាន់សន** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៤០៦.៧៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

លេខ: ៧៦៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោធនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

លោក TRAN VIET HUNG

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.១៤០៦.៧៧៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤

លេខៈ [illegible] ស.ណ
សំណៅចម្លងដែលមានអត្ថន័យត្រឹមត្រូវតាមច្បាប់ដើម ដើម្បីចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៧៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ជូន**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**
- ព្រះតេជគុណ អ៊ុក ស៊ុននឿន

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**
១- ព្រះតេជគុណ នឹម ស៊ាងហ៊ន
២- លោក អាន ស៊ុណា

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**
- ឯកឧត្តម ចេង ពោជ

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**
- លោក កែវ កុសល

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៤០៦.៧៧៥

លេខៈ ៧៧១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០១៤**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤

នស/រកត/០៦១៤/៧៦៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ**ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | |
|---|---|---|
| ១- លោកវរសេនីយ៍ឯក | **ជា ចាន់ឌិន** | អត្តលេខ ០៤៧៨ |
| ២- លោកវរសេនីយ៍ឯក | **ឈឿម ហាប់** | អត្តលេខ ០៥៤២ |
| ៣- លោកវរសេនីយ៍ឯក | **ឆិត្យ ចយ** | អត្តលេខ ០៥៧២ |
| ៤- លោកវរសេនីយ៍ឯក | **ឌឹម យ៉ារ៉ុម** | អត្តលេខ ០១៥៦៣ |
| ៥- លោកវរសេនីយ៍ឯក | **ប៊ួន ចាន់ដាប់** | អត្តលេខ ០១៧៣២ |
| ៦- លោកវរសេនីយ៍ឯក | **ម៉ុម មិន** | អត្តលេខ ០១៧៤៤ |
| ៧- លោកវរសេនីយ៍ឯក | **ជឹម សេងហុង** | អត្តលេខ ០១៧៥០ |
| ៨- លោកវរសេនីយ៍ឯក | **ញ៉ែម សុភី** | អត្តលេខ ០១៧៩១ |
| ៩- លោកវរសេនីយ៍ឯក | **រស់ វណ្ណា** | អត្តលេខ ០១៨០១ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១០- លោកវរសេនីយ៍ឯក **សុខ ពិសិដ្ឋ** អត្តលេខ ០២៣៣៦

១១- លោកវរសេនីយ៍ឯក **សែ សារឿន** អត្តលេខ ០៣៦៣០។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស-១៤០៦.៧៧៩

លេខៈ ៧៩១ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៤*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញា មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៩៣៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(**ម.ម.ជ.**) សម្រាប់ប្រើប្រាស់បំពេញការងារនៅ**ម.ម.ជ.** និងចុះអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជានិងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន សញ្ញាសក្តិ និងមួក

### ផ្នែកទី១

### ឯកសណ្ឋាន

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រី**ម.ម.ជ.** ត្រូវបានកំណត់ជា២(ពីរ)ថ្នាក់ ដូចខាងក្រោម៖

១. ថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នាយកដ្ឋាន ការិយាល័យ សាខា**ម.ម.ជ.** និងមន្ត្រី

ក. ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវ កបើក ថ្នេរខុប ប៉ូលស្មាសងខាង ដឹបចង្កេះ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរបត់ប៉ះផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ និងឡេវមានត្រារូបព្រះសង្ការពណ៌មាស
- អាវដៃវែងពណ៌ខៀវ កបើក ថ្នេរខុប ប៉ូលស្មាសងខាង ដឹបក្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ការពណ៌មាសពីក្រោមរហូតដល់លើ សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួនហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានដឹបក្លីចំនួនពីរ និងមានឆែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌សដៃវែង ក្រវ៉ាត់កពណ៌ក្រហម សម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌ខ្មៅ ដេរថ្នេរបង្កប់ ចង្កេះត ដឹបក្លីខាងមុខពីរ មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធដោតឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ

- ខ្សែក្រវាត់ពណ៌ខ្មៅ។

ខ. ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខ្មៅ ឬសំពត់ហ្សីបពណ៌ខ្មៅ សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

រូបគំរូនៃឯកសណ្ឋាន មានដូចក្នុងឧបសម្ព័ន្ធទី១។

២. ថ្នាក់ភ្នាក់ងារ

ក. ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវ កឧប ថ្នេរឧប បោះឡេវចុងក ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ កាត់ស្រុងវែង ជើងត្រង់ដាក់ក្នុងខោ ហើយឡេវពីមុខនិងឡេវហោប៉ៅមានពណ៌ដូចអាវ
- អាវដៃវែងពណ៌ខៀវ កបើក ថ្នេរឧប ប៉ូលស្មាសងខាង ជីបក្លីខាងមុខពីរ ឡេវធំមានត្រារូបព្រះសង្ហារពណ៌ប្រាក់ពីក្រោមរហូតដល់លើសម្រុងជើងអាវត្រង់ស្មើ ផែកពីក្រោយសងខាងតាមបណ្តោយខ្លួនប្រវែង២៥ស.ម. ហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាលមានគម្របរាងស្លឹកពោធិ៍ ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាលមានគម្របរាងចតុកោណកែង ផ្នែកខាងក្រោយមានជីបក្លីចំនួនពីរ និងមានផែកចំកណ្តាលនៃអាវ។ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុង គឺអាវសឺមីពណ៌ផ្ទៃមេឃ ដៃវែង ក្រវាត់កពណ៌ខៀវសម្រាប់ប្រើក្នុងពិធីការតែប៉ុណ្ណោះ
- ខោជើងវែងពណ៌ខ្មៅ ដេរថ្នេរបង្កប់ ចង្កេះត ជីបក្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់មានគម្របរាងស្លឹកពោធិ៍បោះរន្ធដាក់ឡេវចំនួនមួយ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

ខ. ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី
- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខ្មៅ ឬសំពត់ហ្សីបពណ៌ខ្មៅ សម្រុងក្រោមជង្គង់ ផែកក្រោយ រូតចំហៀង
- ស្បែកជើងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ។

## ផ្នែកទី២
## សញ្ញាសក្តិ

**មាត្រា៣ .-**

សញ្ញាសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម៖

- បាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ
- បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា មានប្រាំបីថ្នាក់ខុសៗគ្នា៖

១. ថ្នាក់ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ"ម.ម.ជ."ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំធំទ្រខាងក្រោម មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី២។

២. ថ្នាក់អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ : មានផ្ទៃពណ៌ស ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ប៉ាក់អក្សរ "ម.ម.ជ." ពណ៌មាស មានក្បាច់អង្គរពណ៌មាសទំហំតូចទ្រខាងក្រោម មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៣។

៣. ថ្នាក់ប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំធំ នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ "ម.ម.ជ."ពណ៌មាស នៅខាងលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងមានរូបព្រះសង្ហារពណ៌មាសនៅខាងចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្សួរវេញ៣(បី) ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៤។

៤. ថ្នាក់អនុប្រធាននាយកដ្ឋាន : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅខាងលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ." ពណ៌មាស នៅខាងលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងរូបព្រះសង្ហារពណ៌មាសនៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញហើយមានខ្សែព្សួរវេញ២(ពីរ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៥។

៥. ថ្នាក់ប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ." ពណ៌មាសនៅលើអក្សរ មានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិពណ៌មាសនៅចំកណ្តាល និងរូបព្រះសង្ហារពណ៌

ពណ៌មាស នៅចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៦។

៦. ថ្នាក់អនុប្រធានការិយាល័យ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌មាសទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ការពណ៌មាសនៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ ១(មួយ)ខ្សែពណ៌មាសព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៧។

៧. ថ្នាក់មន្ត្រី : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ការពណ៌មាស នៅចុងនៃសញ្ញាសក្តិ មានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ១(មួយ) ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះ មានដូចក្នុងឧបសម្ព័ន្ធទី៨។

៨. ថ្នាក់ភ្នាក់ងារ : មានផ្ទៃពណ៌ស នៅផ្នែកខាងក្រោមបង្អស់មានចម្លាក់ក្បាច់អង្គរពណ៌ប្រាក់ទំហំតូច នៅលើក្បាច់នេះមានប៉ាក់អក្សរ"ម.ម.ជ."ពណ៌ប្រាក់ នៅលើអក្សរមានសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិពណ៌ប្រាក់នៅចំកណ្តាល និងរូបព្រះសង្ការពណ៌ប្រាក់នៅចុងនៃសញ្ញាសក្តិមានក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ ហើយមានខ្សែព្ធរវេញ១(មួយ)ខ្សែពណ៌ប្រាក់ព័ទ្ធជុំវិញខាងក្រៅ។ រូបគំរូនៃសញ្ញាសក្តិនេះមានដូចក្នុងឧបសម្ព័ន្ធទី៩។

## ផ្នែកទី៣

## មួក

**មាត្រា៤ .-**

មួកកាស្កែត ត្រូវបានរៀបចំជា៦(ប្រាំមួយ)ថ្នាក់៖

១. ថ្នាក់ប្រធានមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិ : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង ៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការ មានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសដល់ជើងមួក និងខាងក្រោមក្បាច់មានប៉ាក់វណ្ណព្ធរពណ៌មាសពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ ព្រមទាំងនៅខាងចុងខ្សែវណ្ណទាំងពីរខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្លែងក្របីធំដល់ជើងមួក។

២. ថ្នាក់អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិ : មួកកាស្កែតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្តាប់វណ្ណមានភ្ជាប់រូបព្រះសង្ការពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង ៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ការមានប៉ាក់វណ្ណព្ធរពណ៌មាសពីលើកំណាត់

ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ ព្រមទាំងនៅសងខាងចុងខ្សែវណ្ណទាំងពីរខាងភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាស។ ខាងក្រោមនៃប៉ាក់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅនៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេស ប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

៣. ថ្នាក់ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន : មួកកាស្កេតធ្វើពីកំណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើកណ្ដាប់វណ្ណមានភ្ជាប់រូបព្រះសង្ហារពណ៌មាសទំហំកម្ពស់៧,៨ស.ម. ទទឹង៦,៨ស.ម. ផ្នែកខាងក្រោមនៃជើងមួកនិងក្រោមព្រះសង្ហារមានកណ្ដាប់វណ្ណពណ៌មាសនៅពីលើកំណាត់ខ្សែនពណ៌ខៀវព័ទ្ធជុំវិញ។ ខាងក្រោមកណ្ដាប់វណ្ណផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ។ ផ្នែកខាងក្រោមកណ្ដាប់វណ្ណដែលនៅពីលើក្បាំងមានកម្រងខ្សែសយពណ៌មាសនៅខាងចុងកម្រងខ្សែសយទាំងពីរខាងមានភ្ជាប់ឡេវព្រះសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសប៉ាក់ពណ៌មាសទម្រង់ស្នែងក្របីធំដល់ជើងមួក។

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.—**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកព្រៃឈរ នៃខេត្តកំពង់ចាម ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល:__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦ . សសរ

# សេចក្តីសម្រេច

# ស្តីពី

# ការកែសម្រួលសមាសភាពគណៈកម្មការចម្រុះ បង្ក្រាបការលេង ល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៨ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ.បកចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញសេចក្តីសម្រេចលេខ៣៥សសរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មការចម្រុះដើម្បីបង្ក្រាបល្បែងឆ្នោត-ឡូតូ ភ្នាល់បាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោកជំទាវ **ខួន សុខា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. ឯកឧត្តមនាយឧត្តមសេនីយ៍ **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៤. ឯកឧត្តម **សូ ខុចឆ័រ** | ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គនាយកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តមឧត្តមសេនីយ៍ឯក **ឆៃ ស៊ីណារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៧. លោក **រស់ ឥន្ទរុណា** | អគ្គនាយករងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក និងជាលេខាអចិន្ត្រៃយ៍ |
| ៨. ឯកឧត្តមឧត្តមសេនីយ៍ទោ **សៀង សេន** | ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង (កមផ) | សមាជិក និងជាលេខាអចិន្ត្រៃយ៍ |

**ប្រការ ២** គណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១. សហការក្នុងការការពារសិទ្ធិធ្វើអាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុនទាំងឡាយ កំពុងប្រកបអាជីវកម្មកាស៊ីណូ ឆ្នោត-ឡូតូ និងល្បែងភ្នាល់គ្រប់ប្រភេទ ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២. ចាត់វិធានការបង្ក្រាប និងលុបបំបាត់ការធ្វើអាជីកម្មកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់គ្រប់ប្រភេទ ព្រមទាំងអាជីវកម្មរណបផ្សេងៗ ដំណើរការអាជីវកម្មដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣. ចាត់វិធានការបង្ក្រាបអាជីវកម្មទទួលបញ្ជាំ និងប្រាតិភោគដោយអនុប្បទានខុសច្បាប់ទាំងអស់ដែលកំពុងធ្វើអាជីវកម្មដែលគ្មានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** គណៈកម្មការចម្រុះបង្ក្រាបការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និងល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ មានសិទ្ធិបង្កើតអនុគណៈកម្មការសម្រាប់ធ្វើប្រតិបត្តិការបង្ក្រាប

ការលេងល្បែងកាស៊ីណូ ឆ្នោត-ឡូតូ ភ្នាល់បាល់ ភ្នាល់អនឡាញ និង ល្បែងភ្នាល់ខុសច្បាប់គ្រប់ប្រភេទ និងការធ្វើអាជីវកម្មទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានខុសច្បាប់ទាំងអស់នៅតាមរាជធានី-ខេត្តទូទាំងប្រទេស។

**ប្រការ ៤** សេចក្តីសម្រេច និងលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការមួយ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ ១២៥ បទ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ខែធ្នូឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសាឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**ប្រការ ២.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងលេខាធិការដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- រៀបចំមុខងារ និងភារកិច្ចរបស់នាយកដ្ឋាន និងលេខាធិការដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- រៀបចំមុខងារ និងភារកិច្ចរបស់ការិយាល័យនានា ក្រោមឱវាទនាយកដ្ឋាន និងលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងលេខាធិការដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

## ជំពូកទី ២
## បេសកកម្ម និង រចនាសម្ព័ន្ធ

**ប្រការ ៤.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើបេសកកម្មរៀបចំអនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ចូលរួមសហការលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ និងកំណត់និយាមកម្មវិធីកុំព្យូទ័រ និងសន្តិសុខព័ត៌មានលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

**ប្រការ ៥.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានភារកិច្ចដូចតទៅ៖

- រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំលិខិតបទដ្ឋានគតិយុត្តលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ចូលរួមសហការលើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ សកលលោក និងអង្គការអន្តរជាតិ
- ចូលរួមរៀបចំ និងគ្រប់គ្រងប្រព័ន្ធសន្តិសុខព័ត៌មាន និងសុវត្ថិភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បង្កើតប្រព័ន្ធជូនដំណឹងជាមុនអំពីសន្តិសុខព័ត៌មាន
- រៀបចំដាក់ឲ្យដំណើរការមជ្ឈមណ្ឌលជាតិទទួលបន្ទុកការងារសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ និងអភិវឌ្ឍសួនឧស្សាហកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

- គ្រប់គ្រង និងផ្សព្វផ្សាយការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាននៅក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់ និងកម្មវិធីកុំព្យូទ័រ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធការងារនៃរដ្ឋាភិបាលអេឡិកត្រូនិច
- គ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រព័ន្ធ MIS និង Website របស់ក្រសួង
- អភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារជូនក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ឱ្យ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច
- នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- លេខាធិការដ្ឋាន។

**ប្រការ ៧.-**

នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងាររដ្ឋាភិបាលអេឡិកត្រូនិច។

នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងារគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងារគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល។

នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងារកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន។

នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋាន បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន លើការងារសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងារឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ។

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន លើការសម្របសម្រួលរាល់សកម្មភាពការងាររបស់អគ្គនាយកដ្ឋាន។

**ប្រការ ៨.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

លេខាធិការដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ពាក្យគន្លឹះ និងអង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៣
## នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច

**ប្រការ ៩.-**

នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច មានមុខងារ និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- ផ្តួចផ្តើមគំនិតអភិវឌ្ឍកម្មវិធីកុំព្យូទ័រសម្រាប់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- កំណត់និយាមកម្មវិធីកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រសម្រាប់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- បង្កើត និងរៀបចំឲ្យមានមាតិកាព័ត៌មានគំរូ និងជាភាសាខ្មែរក្នុងរដ្ឋាភិបាលអេឡិកត្រូនិច ដោយប្រើប្រាស់ពុម្ពអក្សរខ្មែរយូនីកូដ
- ជំរុញឲ្យមានការបង្កើតគេហទំព័រ និងការប្រើប្រាស់សារអេឡិកត្រូនិចជាភាសាខ្មែរជាចម្បងនៅតាមក្រសួង ស្ថាប័ន
- ផ្តល់ប្រឹក្សាដល់គ្រប់ស្ថាប័នក្នុងការស្ថាបនាប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- សហការជាមួយស្ថាប័នផ្សេងៗក្នុងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១០.-**

នាយកដ្ឋានរដ្ឋាភិបាលអេឡិកត្រូនិច មានការិយាល័យចំណុះចំនួន០៥(ប្រាំ)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យស្តង់ដារ
- ការិយាល័យគេហទំព័រ
- ការិយាល័យប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច

- ការិយាល័យប្រតិបត្តិការប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច។

**ប្រការ ១១.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង និងរៀបចំមាតិកាព័ត៌មានលើគេហទំព័រ និងប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១២.-**

ការិយាល័យស្តង់ដារ មានភារកិច្ច ៖

- ផ្សព្វផ្សាយអំពីស្តង់ដារប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- កំណត់និយាមកម្មវិធីកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រសម្រាប់រដ្ឋាភិបាលអេឡិកត្រូនិច
- បង្កើតប្រព័ន្ធរក្សាផ្ទុកទិន្នន័យរួម និងប្រព័ន្ធចែករំលែកការប្រើប្រាស់
- បង្កើត និងរៀបចំឲ្យមានមាតិកាព័ត៌មានគំរូ និងជាភាសាខ្មែរដោយប្រើប្រាស់ពុម្ពអក្សរខ្មែរយូនីកូដ
- សិក្សា រៀបចំចងក្រងស្តង់ដារ កំណត់លេខកូដជាតិ និងផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១៣.-**

ការិយាល័យគេហទំព័រ មានភារកិច្ច ៖

- ជំរុញឲ្យមានការបង្កើតគេហទំព័រ និងការប្រើប្រាស់សារអេឡិកត្រូនិចជាភាសាខ្មែរជាចម្បង នៅតាមបណ្តាក្រសួង ស្ថាប័ន
- គ្រប់គ្រង និងសហការអភិវឌ្ឍប្រព័ន្ធគេហទំព័រតាមបណ្តាក្រសួង ស្ថាប័ន
- ផ្តល់សេវាប្រឹក្សាបច្ចេកទេសគេហទំព័រ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១៤.-**

ការិយាល័យប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច មានភារកិច្ច ៖

- ផ្សព្វផ្សាយអំពីប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- ផ្តួចផ្តើមគំនិតអភិវឌ្ឍកម្មវិធីកុំព្យូទ័រសម្រាប់ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- គ្រប់គ្រង និងសហការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច

- ផ្តល់ប្រឹក្សាដល់គ្រប់ស្ថាប័នក្នុងការស្ថាបនាប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- សិក្សាស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១៥.-**

ការិយាល័យប្រតិបត្តិការប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច មានភារកិច្ច ៖

- គ្រប់គ្រង ដំឡើង និងថែទាំប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- ផ្តល់សេវាដំណើរការប្រព័ន្ធគេហទំព័រ និងសារអេឡិកត្រូនិច
- គ្រប់គ្រង និងរៀបចំប្រព័ន្ធម៉ាស៊ីនមេសម្រាប់ដំណើរការប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិច
- គ្រប់គ្រង និងរៀបចំប្រព័ន្ធបង្ការ និងការពារទិន្នន័យប្រព័ន្ធគេហទំព័រ សារអេឡិកត្រូនិច និង ប្រព័ន្ធរដ្ឋាភិបាលអេឡិកត្រូនិចផ្សេងៗទៀត
- សិក្សាស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៤
## នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ប្រការ ១៦.-**

នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មានសម្រាប់រយៈពេលខ្លី មធ្យម និងវែងដោយសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សិក្សា និងវាយតម្លៃលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍវិស័យ បច្ចេក-វិទ្យាគមនាគមន៍ និងព័ត៌មាន
- ប្រមូល និងរៀបចំចងក្រងទិន្នន័យទាងឡាយទាក់ទងនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យានិង ព័ត៌មាន។
- ផ្សព្វផ្សាយ និងជំរុញការអភិវឌ្ឍគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្តល់សេវាពិគ្រោះយោបល់លើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន

- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១៧.-**

នាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានការិយាល័យចំណុះចំនួន០៤(បួន)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យរៀបចំគោលនយោបាយ
- ការិយាល័យរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព
- ការិយាល័យតាមដាន ត្រួតពិនិត្យនិងប្រឹក្សាយោបល់។

**ប្រការ ១៨.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច៖

- សម្របសម្រួលរាល់សកម្មភាពរបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ប្រមូល និងរៀបចំចងក្រងទិន្នន័យទាងឡាយទាក់ទងនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យា និងព័ត៌មាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ១៩ .-**

ការិយាល័យរៀបចំគោលនយោបាយ មានភារកិច្ច៖

- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់រយៈពេលខ្លី មធ្យម និងវែងដោយសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន
- ផ្សព្វផ្សាយ និងជំរុញការអភិវឌ្ឍគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២០.-**

ការិយាល័យរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព មានភារកិច្ចៈ

- រៀបចំយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្សព្វផ្សាយ និងជំរុញការអភិវឌ្ឍយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្ដីពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២១.-**

ការិយាល័យតាមដាន ត្រួតពិនិត្យ និងប្រឹក្សាយោបល់ មានភារកិច្ចៈ

- ពិនិត្យ តាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍវិស័យ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់រយៈពេលខ្លី មធ្យម និង វែង
- សិក្សា និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្ដល់សេវាពិគ្រោះយោបល់ស្ដីពីគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៥
## នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល

**ប្រការ ២២.-**

នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ចដូចតទៅៈ

- អភិវឌ្ឍន៍ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- ផ្សព្វផ្សាយ និងជំរុញឲ្យមានការចូលរួមថែទាំ និងការពារហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលការងារបច្ចេកទេសជាមួយក្រសួង ស្ថាប័ន លើការតភ្ជាប់បណ្ដាញ ការប្រើប្រាស់សេវាអ៊ីនធឺណេត និងការប្រើប្រាស់ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលកិច្ចសហការជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍនានា
- គ្រប់គ្រងមជ្ឈមណ្ឌលប្រតិបត្តិការបណ្ដាញ មជ្ឈមណ្ឌលទិន្នន័យបណ្ដាញ និងមជ្ឈមណ្ឌលគាំទ្របច្ចេកទេសបណ្ដាញ

- រៀបចំផ្តល់សេវាបច្ចេកទេសពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធវីដេអូនៃសន្និសីទជូនស្ថាប័នផ្សេងៗ
- ផ្តល់សេវាពិគ្រោះយោបល់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៣.-**

នាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលមានការិយាល័យចំណុះចំនួន០៦(ប្រាំមួយ)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យប្រតិបត្តិការបណ្តាញ
- ការិយាល័យគាំទ្របច្ចេកទេសបណ្តាញ
- ការិយាល័យប្លង់ និងរូបសណ្ឋានបណ្តាញ
- ការិយាល័យសម្ភារៈបច្ចេកទេសបណ្តាញ
- ការិយាល័យប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល។

**ប្រការ ២៤.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំប្រព័ន្ធព័ត៌មាននានាសម្រាប់ប្រើប្រាស់ក្នុងនាយកដ្ឋាន ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានឧបករណ៍សម្ភារៈ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអ្នកប្រើប្រាស់បណ្តាញ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសកម្មភាពការងារ ប្រព័ន្ធតាមដាន និងត្រួតពិនិត្យព័ត៌មានបណ្តាញ និងប្រព័ន្ធគ្រប់គ្រងឯកសារបណ្តាញជាដើម
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៥.-**

ការិយាល័យប្រតិបត្តិការបណ្តាញ មានភារកិច្ច ៖

- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នដែលពាក់ព័ន្ធក្នុងការរៀបចំ និងថែទាំហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ

- តាមដាន និងត្រួតពិនិត្យជាប្រចាំលើប្រព័ន្ធបណ្តាញក្នុងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- ថែទាំឧបករណ៍សម្ភារៈទាំងអស់ដែលពាក់ព័ន្ធការងារហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- ឆ្លើយតប និងដោះស្រាយជាបន្ទាន់នូវរាល់បញ្ហាដែលពាក់ព័ន្ធលើការប្រើប្រាស់សេវាហេដ្ឋា-រចនាសម្ព័ន្ធព័ត៌មានជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៦.-**

ការិយាល័យគាំទ្របច្ចេកទេសបណ្តាញ មានភារកិច្ច ៖

- សិក្សាស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និង ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវ និងកំណត់និយាមសម្រាប់ការអភិវឌ្ឍន៍ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- ប្រមូលរៀបចំ និងចងក្រងឯកសារបច្ចេកទេសនានា
- គ្រប់គ្រងបន្ទប់ពិសោធន៍ផ្ទៃក្នុង
- ចូលរួមសហការស្រាវជ្រាវជាមួយបណ្តាក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យឯកជន
- ផ្តល់សេវាពិគ្រោះយោបល់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៧.-**

ការិយាល័យប្លង់ និងរូបសណ្ឋានបណ្តាញ មានភារកិច្ច ៖

- រៀបចំប្លង់ និងរូបសណ្ឋានបណ្តាញក្នុងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- រៀបចំ និងដំឡើងឧបករណ៍ទាំងអស់ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលទិន្នន័យបណ្តាញ
- រៀបចំក្រុមការងារបច្ចេកទេសដើម្បីជួយដោះស្រាយរាល់បញ្ហាដែលពាក់ព័ន្ធជាមួយប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- រៀបចំឯកសារបច្ចេកទេសអំពីរបៀបដំឡើង និងប្រើប្រាស់ឧបករណ៍នីមួយៗ
- ទទួលខុសត្រូវលើរាល់សុវត្ថិភាពរបស់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- គ្រប់គ្រងលើការបែងចែក អាសយដ្ឋានអាយភី និងការបែងចែកសេវាអ៊ីនធឺណេត
- គ្រប់គ្រងលើសេវាបណ្តាញផ្សេងៗនៅក្នុងមជ្ឈមណ្ឌលទិន្នន័យបណ្តាញ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៨.-**

ការិយាល័យសម្ភារៈបច្ចេកទេសបណ្តាញ មានភារកិច្ច ៖

- រៀបចំផែនការការងារសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- រៀបចំគម្រោងទិញសម្ភារៈផ្សេងៗសម្រាប់ប្រើប្រាស់នៅក្នុងនាយកដ្ឋាន
- គ្រប់គ្រងរក្សាទុកសម្ភារៈបច្ចេកទេសទាំងអស់ដែលពាក់ព័ន្ធ

- ផ្តល់សម្ភារៈទៅដល់ផ្នែក ឬការិយាល័យដែលពាក់ព័ន្ធ
- ថែទាំ និងជួសជុលឡើងវិញនូវរាល់ឧបករណ៍សម្ភារៈផ្សេងៗដែលខូចខាត
- រៀបចំរបាយការណ៍ស្តីពីសម្ភារៈដែលមាន និងតម្រូវការទិញបន្ថែម
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ២៩.-**

ការិយាល័យប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល មានភារកិច្ច ៖

- ត្រួតពិនិត្យ និងតាមដានឧបករណ៍ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលតាមបណ្តារាជធានី ខេត្ត អង្គភាពយោធា អង្គភាពនគរបាល និងទីតាំងផ្សេងៗដែលបានបំពាក់ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រព័ន្ធបញ្ជារបស់ប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល
- សហការ និងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធជាមួយឧបករណ៍ប្រព័ន្ធវីដេអូនៃសន្និសីទ តាមបណ្តារាជធានី ខេត្ត អង្គភាពយោធា អង្គភាពនគរបាល និងទីតាំងផ្សេងៗ
- សហការជាមួយក្រុមហ៊ុនដែលជាដៃគូ
- រៀបចំធ្វើការសាកល្បងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលរៀងរាល់សប្តាហ៍
- រៀបចំបញ្ជាប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលរៀងរាល់ពេលនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
- រៀបចំវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីបច្ចេកទេស
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៦
## នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

**ប្រការ ៣០.-**

នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន មានមុខងារ និងភារកិច្ចដូចតទៅ៖

- ជំរុញ និងគ្រប់គ្រងការបង្កើតកម្រងកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ជំរុញ និងគ្រប់គ្រងឧស្សាហកម្មកម្មវិធីកុំព្យូទ័រ
- កំណត់និយាមទម្រង់អក្សរខ្មែរយូនីកូដ និងក្តារចុច
- រៀបចំឲ្យមានស្តង់ដាកម្មវិធីកុំព្យូទ័រ
- រៀបចំបែបបទផ្តល់អាជ្ញាប័ណ្ណសម្រាប់ក្រុមហ៊ុនផលិតកម្មវិធីកុំព្យូទ័រ
- ផ្តល់សេវាប្រឹក្សាបច្ចេកទេសផ្នែកកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ធ្វើការត្រួតពិនិត្យកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មានតាមបណ្តាស្ថាប័ន អង្គការនិង ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្រទទួលស្គាល់គុណភាពកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន

- ចេញលិខិតបញ្ជាក់ លិខិតសរសើរអំពីគុណភាពកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន ដល់បណ្តាក្រុមហ៊ុន អង្គភាពដែលអនុវត្តបានតាមកម្រិតស្តង់ដារជាតិ និងអន្តរជាតិ
- ផ្សព្វផ្សាយ និងពង្រឹងកម្មសិទ្ធិបញ្ញាលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣១.-**

នាយកដ្ឋានកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន មានការិយាល័យចំណុះចំនួន ០៥(ប្រាំ)៖

- ការិយាល័យ រដ្ឋបាល
- ការិយាល័យ អភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ការិយាល័យ ប្រឹក្សាបច្ចេកទេសកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ការិយាល័យ ត្រួតពិនិត្យកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ការិយាល័យ ចុះបញ្ជី និងផ្តល់អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន។

**ប្រការ ៣២.-**

ការិយាល័យ រដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣៣.-**

ការិយាល័យប្រឹក្សាបច្ចេកទេសកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន៖

- ផ្តល់សេវាប្រឹក្សាបច្ចេកទេសដល់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យឯកជន លើផ្នែកកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- សហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការសិក្សាគម្រោងផ្សេងៗ ដែលពាក់ព័ន្ធ ផ្នែកកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣៤.-**

ការិយាល័យត្រួតពិនិត្យកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន មានភារកិច្ច ៖

- ស្រាវជ្រាវ និងកំណត់និយាមសម្រាប់កម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- ត្រួតពិនិត្យកម្រងកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន តាមបណ្តាក្រសួងស្ថាប័ន អង្គការ និងក្រុមហ៊ុន
- ផ្តល់របាយការណ៍ មតិយោបល់ និងដំណោះស្រាយដល់ស្ថាប័ន អង្គការ និងក្រុមហ៊ុននានាបន្ទាប់ពីបានត្រួតពិនិត្យរួចរាល់
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣៥.-**

ការិយាល័យចុះបញ្ជី និងផ្តល់អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រនិងមាតិកាព័ត៌មាន មានភារកិច្ច ៖

- ចុះបញ្ជីផ្តល់ និងផ្តល់អាជ្ញាប័ណ្ណសម្រាប់ក្រុមហ៊ុនផលិតកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- គ្រប់គ្រងស្ថិតិក្រុមហ៊ុនផលិតកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- រៀបចំកម្មវិធីសម្រាប់លើកទឹកចិត្តដល់ក្រុមហ៊ុនផលិតកម្មវិធីកុំព្យូទ័រទាំងឡាយណាដែលបានចុះបញ្ជីអាជ្ញាប័ណ្ណត្រឹមត្រូវ តាមរយៈការពង្រឹងកម្មសិទ្ធិបញ្ញា
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣៦.-**

ការិយាល័យអភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន មានភារកិច្ច ៖

- រៀបចំបង្កើតកម្រងកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- សិក្សាស្រាវជ្រាវ និងរៀបចំផែនការរយៈពេលខ្លី មធ្យម និងវែង ដើម្បីអភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មាន
- រៀបចំស្តង់ដារជាតិសម្រាប់កម្រងកម្មវិធីកុំព្យូទ័រនិងមាតិកាព័ត៌មាន
- ផ្តល់សេវាថែទាំកម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មានតាមបណ្តាស្ថាប័ន អង្គការ និងក្រុមហ៊ុន
- ផ្សព្វផ្សាយបច្ចេកវិទ្យាកុំព្យូទ័រថ្មីៗដែលផ្តល់អត្ថប្រយោជន៍ដល់កំណើនសេដ្ឋកិច្ចជាតិ
- ជំរុញនិងលើកកម្ពស់ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ និងមាតិកាព័ត៌មានដែលមានលក្ខណៈ ត្រឹមត្រូវតាមស្តង់ដារជាតិនិងអន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៧
## នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ប្រការ ៣៧.-**

នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារ និងភារកិច្ចដូចតទៅ៖

- សិក្សា និងរៀបចំនិយាម គោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បង្កើតប្រព័ន្ធជូនដំណឹងជាមុនពីសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ និងមជ្ឈមណ្ឌលជាតិទទួលបន្ទុកការងារសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ដើរតួនាទីជាអង្គភាពជំនាញផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់កិច្ចសហប្រតិបត្តិការជាមួយក្រុមការងារសន្តិសុខនានានៅក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជានៅជុំវិញពិភពលោក
- ប្រមូល តាមដាន សិក្សាស្រាវជ្រាវ និងចូលរួមទប់ស្កាត់បទល្មើសគំរាមកំហែងគ្រប់ប្រភេទតាមបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំចេញវិញ្ញាបនបត្រទទួលស្គាល់កម្រិតនិយាម សន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើការត្រួតពិនិត្យទៅលើវិស័យសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅតាមក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជន
- សហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសន្តិសុខ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្តល់ការប្រឹក្សាលើវិស័យសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង ផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទៅដល់ក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជន
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៣៨.-**

នាយកដ្ឋានសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានការិយាល័យចំណុះចំនួន០៥(ប្រាំ)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ
- ការិយាល័យធានាគុណភាព និងកោសលវិច្ច័យឌីជីថល
- ការិយាល័យនិយាម ត្រួតពិនិត្យ និងហានិភ័យ
- ការិយាល័យហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ។

**ប្រការ ៣៩.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន

- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ចងក្រងឯកសារ ធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងស្តីពីសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំផ្សព្វផ្សាយ បទប្បញ្ញត្តិ សេចក្តីណែនាំ លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ
- សហការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលាជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ការយល់ដឹងអំពី សន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤០.-**

ការិយាល័យឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ មានភារកិច្ច ៖

- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារស្តីពីការវាយប្រហារមកលើហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ និង ម៉ាស៊ីនមេរបស់រាជរដ្ឋាភិបាល
- រៀបចំប្រព័ន្ធជូនដំណឹងជាមុនស្តីពីសន្តិសុខព័ត៌មាន
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័រ និងសារអេឡិកត្រូនិចរបស់ការិយាល័យទប់ទល់បញ្ហាបន្ទាន់នៃកុំព្យូទ័រនៅកម្ពុជា
- ត្រួតពិនិត្យចរាចរទិន្នន័យ ដែលវាយប្រហារមកលើម៉ាស៊ីនមេរបស់រាជរដ្ឋាភិបាល និងឯកជន
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ ដើម្បីបង្កើនសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហប្រតិបត្តិការជាមួយក្រុមការងារសន្តិសុខផ្សេងៗទៀតនៅក្នុងតំបន់ និងពិភពលោក
- គ្រប់គ្រងមជ្ឈមណ្ឌលជាតិទទួលបន្ទុកការងារសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤១.-**

ការិយាល័យធានាគុណភាព និងកោសល្យវិច័យឌីជីថល មានភារកិច្ច ៖

- ត្រួតពិនិត្យលើរាល់កម្មវិធីទាំងអស់ដែលមានបំណងតភ្ជាប់ជាមួយហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- តាមដាន វិភាគ និងធ្វើកោសល្យវិច័យទៅលើបញ្ហាផ្សេងៗដែលកើតមានឡើង នៅក្នុងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- ស្វែងរកចំណុចខ្សោយនៅក្នុងគេហទំព័ររបស់រាជរដ្ឋាភិបាល និងស្ថាប័នរដ្ឋផ្សេងៗទៀត និងលើកអនុសាសន៍ ដើម្បីធ្វើឲ្យប្រសើរឡើង
- ចូលរួមទប់ស្កាត់ការវាយប្រហារមកលើហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ
- រៀបចំកន្លែងពិសោធន៍សម្រាប់ធ្វើការសិក្សាវិភាគរកចំណុចខ្សោយផ្សេងៗ

- ផ្ដល់ប្រឹក្សា និងចេញវិញ្ញាបនប័ត្រទទួលស្គាល់កម្រិតគុណភាព និងសុវត្ថិភាពនៃកម្មវិធីកុំព្យូទ័រជូនវិស័យឯកជន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤២.-**

ការិយាល័យនិយាម ត្រួតពិនិត្យ និងហានិភ័យ មានភារកិច្ច ៖

- សិក្សានិងរៀបចំ និយាម គោលនយោបាយ ហានិភ័យ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ត្រួតពិនិត្យទៅលើប្រព័ន្ធសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់ក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជន
- សហការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីវិធានសន្តិសុខបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន
- ចេញវិញ្ញាបនបត្រទទួលស្គាល់កម្រិតនិយាម សន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤៣.-**

ការិយាល័យហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ មានភារកិច្ច ៖

- ផ្ដល់សេវាប្រឹក្សាយោបល់លើផ្នែកវិញ្ញាបនបត្រឌីជីថល និង ហត្ថលេខាឌីជីថល
- គ្រប់គ្រងរាល់ការងារដែលពាក់ព័ន្ធនិងការចេញ ត្រួតពិនិត្យ និងដកហូតអាជ្ញាប័ណ្ណ របស់អង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថល
- សិក្សា និងផ្ដល់អាជ្ញាប័ណ្ណជូនអង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថលនិងហត្ថលេខាឌីជីថល
- គ្រប់គ្រង ត្រួតពិនិត្យ និងចេញលិខិតអនុញ្ញាតជូនអង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថល
- បញ្ជាក់លើការទទួលស្គាល់រាល់ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំគោលការណ៍ណែនាំ សម្រាប់កំណត់លក្ខខណ្ឌ និងកម្រិតបទដ្ឋានបច្ចេកវិទ្យាចាំបាច់ដើម្បីរេចក្លាយទៅជាអង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថល
- គ្រប់គ្រងទិន្នន័យវិញ្ញាបនបត្រឌីជីថលទាំងអស់ដែលបានផ្ដល់ដោយអង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថល
- សហប្រតិបត្តិការជាមួយអង្គភាពបញ្ជាក់វិញ្ញាបនបត្រឌីជីថលរបស់ប្រទេសនានានៅក្នុងតំបន់និងពិភពលោក
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៨
## នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ប្រការ ៤៤.-**

នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានមុខងារ និងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងអភិវឌ្ឍឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញអភិវឌ្ឍឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការ និងរៀបចំផ្តល់លិខិតអនុញ្ញាត្ត លើការរៀបចំពិព័រណ៍ពាណិជ្ជកម្ម
- សហការ និងរៀបចំផ្តល់អាជ្ញាប័ណ្ណ ជំនួញឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញអភិវឌ្ឍ និងគ្រប់គ្រងសួនឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញរៀបចំផ្សព្វផ្សាយ និងគ្រប់គ្រងពិព័រណ៍ពាណិជ្ជកម្ម និងដំណើរទេស្សនកិច្ច បង្ហាញពីមុខរបរ ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- លើកកម្ពស់តួនាទី និងភាពចាំបាច់របស់ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- ទាក់ទាញការវិនិយោគ លើការច្នៃប្រឌិត និងស្រាវជ្រាវបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញ និងសម្របសម្រួលការងារសហប្រតិបត្តិការទ្វេភាគី ឬ ពហុភាគីលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជាមួយបណ្តាប្រទេសក្នុងតំបន់ សកលលោក និងអង្គការអន្តរជាតិនានា
- ផ្តល់ប្រឹក្សាដល់គ្រប់ស្ថាប័នពាក់ព័ន្ធ លើការងារទាក់ទងនឹងឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- បង្កើតយន្តការតាមដាន និងវាយតម្លៃ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- កែលម្អ ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឲ្យស្របទៅតាមនិយាមអន្តរជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤៥.-**

នាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានការិយាល័យចំណុះចំនួន០៤(បួន)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យលើកកម្ពស់ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ការិយាល័យជំរុញការវិនិយោគ និងពាណិជ្ជកម្ម
- ការិយាល័យសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ៤៦.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពរបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន

- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤៧.-**

ការិយាល័យលើកកម្ពស់ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានភារកិច្ច ៖

- ជំរុញការកសាងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទាក់ទងនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញរៀបចំ និងអភិវឌ្ឍសួនឧស្សាហកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងស្ថាប័នរាជរដ្ឋាភិបាល សហគ្រាសធុនតូច និងមធ្យម
- បង្កើតយន្តការតាមដាន និងវាយតម្លៃ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបៃតង
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤៨.-**

ការិយាល័យជំរុញការវិនិយោគនិងពាណិជ្ជកម្ម មានភារកិច្ច ៖

- គាំទ្រការបង្កើតមុខជំនួញឧស្សាហកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការ និងរៀបចំផ្តល់លិខិតអនុញ្ញាតលើការរៀបចំពិព័រណ៍ពាណិជ្ជកម្ម
- សហការ និងរៀបចំផ្តល់អាជ្ញាប័ណ្ណលើជំនួញឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ជំរុញការងាររៀបចំផ្សព្វផ្សាយ និងគ្រប់គ្រងពិព័រណ៍ពាណិជ្ជកម្ម និងដំណើរទស្សនកិច្ច បង្ហាញអំពីមុខរបរ វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សម្របសម្រួល ការបង្កើតប្រព័ន្ធទិន្នន័យគ្រប់គ្រងពាណិជ្ជកម្ម
- ទាក់ទាញការវិនិយោគ លើការច្នៃប្រឌិត និងស្រាវជ្រាវបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្តល់ប្រឹក្សាដល់គ្រប់ស្ថាប័នពាក់ព័ន្ធ លើការងារទាក់ទងនឹងឧស្សាហកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ផ្តួចផ្តើមគំនិតថ្មីៗ អំពីវិធីសាស្ត្រអនុវត្តគម្រោងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ចែកជូនសហគ្រាសធុនតូច និងមធ្យម
- កែលម្អ ស្ថិតិវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឲ្យស្របទៅតាមនិយាមអន្តរជាតិ
- ចងក្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ចងក្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យអ្នកជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៤៩.-**

ការិយាល័យសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ៖

- សហការ និងសម្របសម្រួលការងារសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាមួយបណ្តាប្រទេសក្នុងតំបន់ សកលលោក និងអង្គការអន្តរជាតិនានា
- បង្កើតកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាអង្គការអន្តរជាតិ និងក្រុមហ៊ុនឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីចែករំលែកចំណេះដឹង និងចំណេះធ្វើជាមួយកម្ពុជា
- សហការរៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាពអភិវឌ្ឍ វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ធ្វើបច្ចុប្បន្នភាពជូនប្រមុខរាជរដ្ឋាភិបាល ស្ថាប័នជាតិ និងអន្តរជាតិអំពីការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ៩
## នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ

**ប្រការ ៥០.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ មានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំ និងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- សហការរៀបចំគោលនយោបាយ និងអនុវត្តកាតព្វកិច្ចសេវាសកល
- សហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល
- រៀបចំ និងអភិវឌ្ឍមាតិកាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ផ្សព្វផ្សាយឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជូនប្រជាជននៅជនបទ
- ទទួលជំនួយកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ដៃគូអភិវឌ្ឍ ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- រៀបចំបណ្តុះបណ្តាលប្រជាជននៅជនបទ អំពីវិធីសាស្ត្រថ្មីៗ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានប្រកបដោយប្រសិទ្ធភាព
- រៀបចំ និងចងក្រងទិន្នន័យសេវាសកល
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៥១.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ មានការិយាល័យចំណុះចំនួន ០៤(បួន)៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យកាតព្វកិច្ចសេវាសកល
- ការិយាល័យអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ការិយាល័យជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ។

**ប្រការ ៥២.-**

ការិយាល័យរដ្ឋបាល មានភារកិច្ច ៖

- សម្របសម្រួលរាល់សកម្មភាពការងាររបស់នាយកដ្ឋាន
- គ្រប់គ្រង ចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់នាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់នាយកដ្ឋាន
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងនាយកដ្ឋាន
- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៥៣.-**

ការិយាល័យកាតព្វកិច្ចសេវាសកល មានភារកិច្ច ៖

- អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល
- រៀបចំ និងសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលសំដៅជំរុញ និងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដល់ទីជនបទ
- សហការរៀបចំ និងបង្កើតនិយាម ដើម្បីអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលសម្រាប់ជនបទ
- ចូលរួមរៀបចំយុទ្ធសាស្ត្រ និងផែនការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកល
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៥៤.-**

ការិយាល័យអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ៖

- រៀបចំ និង បង្កើតនិយាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- រៀបចំ និងអភិវឌ្ឍមាតិកាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- រៀបចំ និងចងក្រងឯកសារបច្ចេកទេសអំពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ

- រៀបចំ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅជនបទ
- រៀបចំ និងបង្កើតមជ្ឈមណ្ឌលទូរគមនាគមន៍ជនបទ ឬ យន្តការនានា ដើម្បីផ្តល់សេវាចែករំលែកព័ត៌មាននៅជនបទ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

**ប្រការ ៥៥.-**

ការិយាល័យជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ មានភារកិច្ច ៖

- សហការរៀបកិច្ចប្រជុំ សិក្ខាសាលាជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ជំរុញលើកទឹកចិត្តប្រជាជនឱ្យចូលរួមប្រើប្រាស់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅជនបទ
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីបង្កើនសមត្ថភាព និងបញ្ជ្រាបចំណេះដឹងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជូនប្រជាជននៅជនបទ
- រៀបចំ និងចងក្រងទិន្នន័យសម្រាប់វិស័យដែលមានសក្តានុពល ក្នុងការប្រើប្រាស់ និងចែករំលែកព័ត៌មានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់ជនបទ
- ផ្សព្វផ្សាយ និងជំរុញប្រជាជននៅជនបទឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ១០
## លេខាធិការដ្ឋាន

**ប្រការ ៥៦.-**

លេខាធិការដ្ឋាន មានមុខងារ និងភារកិច្ចដូចតទៅ ៖

- រៀបចំចងក្រង ថែរក្សាពល់ឯកសាររបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំ ពិនិត្យ និងយោបល់លើរាល់ឯកសារ សេចក្តីព្រាងសំណើ សំណុំលិខិតផ្សេងៗ មុននឹងដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- តាមដាន និងសម្របសម្រួលការងារជាមួយនាយកដ្ឋាន និងអង្គភាពនានាដែលស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងត្រារបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- គ្រប់គ្រងសន្និធិ និងទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋាន
- រៀបចំ ផែនការសកម្មភាព និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- រៀបចំកិច្ចប្រជុំការងារផ្ទៃក្នុងរបស់អគ្គនាយកដ្ឋាន និងកិច្ចប្រជុំការងារនានា

- សរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់លេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និង ប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៥៧.-**

ក្នុងពេលបំពេញការងារ ភារកិច្ចទាំងឡាយណាដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លើការកំណត់បែងចែកភារកិច្ចទាំងនោះ។

**ប្រការ ៥៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥៩.-**

ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៩
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ ភ្ជាប់ប្រកាសលេខ...១២៥...បទ.ប្រក ចុះថ្ងៃទី...០៧...ខែ...មិថុនា...ឆ្នាំ២០១៤

**អង្គការលេខរបស់អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**



ឧបសម្ព័ន្ធ២ ភ្ជាប់ប្រកាសលេខ......១២៥......បទ.ប្រក ចុះថ្ងៃទី..០២.. ខែ..មិថុនា.. ឆ្នាំ២០១៤

## ពាក្យគន្លឹះប្រើប្រាស់ក្នុងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាព
## ក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

- Early Warning System (ប្រព័ន្ធជូនដំណឹងជាមុន)៖ គឺជាប្រព័ន្ធសម្រាប់ផ្តល់ ដំណឹងជាមុនអំពីការវាយប្រហារតាមបណ្តាញ និងប្រព័ន្ធអ៊ីនធឺណេត
- Public Key Infrastructure(រចនាសម្ព័ន្ធគន្លឹះសាធារណៈ)៖ គឺជាសំណុំគោលនយោបាយ នីតិវិធីដែល ត្រូវការសម្រាប់បង្កើត គ្រប់គ្រង ចែកចាយ ប្រើប្រាស់រក្សាទុកនិងដកហូតវិញ្ញាបនបត្រឌីជីថល។
- Digital Forensic(កោសលវិច័យឌីជីថល)៖ គឺជាការតាមដានរកស្លាកស្នាម កស្តុតាង នៃការជ្រៀតចូល ឬការវាយប្រហារទៅក្នុងប្រព័ន្ធ។
- Traffic Monitoring(ត្រួតពិនិត្យចរាចរទិន្នន័យ)៖ ជាការតាមដានឃ្លាំមើលចរាចរទិន្នន័យរបស់បណ្តាញ
- Vulnerability(ចំណុចខ្សោយ)៖ ភាពងាយរងគ្រោះ ដែលមាននៅក្នុងប្រព័ន្ធ និងកម្មវិធី។
- Digital Certificate(វិញ្ញាបនបត្រឌីជីថល)៖ ជាឯកសារអេឡិកត្រូនិច ដែលអាចឱ្យមនុស្សម្នាក់ឬកុំព្យូទ័រ ឬអង្គភាពមួយធ្វើការផ្លាស់ប្តូរព័ត៌មានដោយសុវត្ថិភាពតាមបណ្តាញអ៊ីនធឺណេត ដោយប្រើហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ។
- Digital Signature(ហត្ថលេខាឌីជីថល)៖ គឺជាព័ត៌មានដែលបង្ហាញនូវភាពត្រឹមត្រូវនៃឯកសារ។
- Tele-Center ( មណ្ឌលទូរគមនាគមន៍)៖ ជាមណ្ឌលសម្រាប់ផ្តល់សេវាព័ត៌មានទូទៅ ទូរស័ព្ទ ប្រៃសណីយ៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន សម្រាប់ជនបទ។
- Universal Service Obligation(USO) (កាតព្វកិច្ចសេវាសកល)៖ ជាកាតព្វកិច្ចរបស់ក្រុមហ៊ុនទូរគមនាគមន៍ ត្រូវអនុវត្តដើម្បីធានាថា ប្រជាជនទោះនៅក្នុងទីក្រុងឬជនបទ អាចប្រើប្រាស់សេវាបាននៅគ្រប់ទីកន្លែង។
- IP Address (អាសយដ្ឋានអាយភី)៖ គឺជាលេខសំគាល់ឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលត្រូវបានប្រើប្រាស់ដើម្បីឲ្យឧបករណ៍នោះអាចទំនាក់ទំនងគ្នាបាន នៅលើបណ្តាញកុំព្យូទ័រ ឬនៅលើ បណ្តាញអ៊ីនធឺណេត។
- Cloud Computing (បច្ចេកវិទ្យាពពក)៖ គឺជាបច្ចេកវិទ្យាមួយ ដែលបានប្រមូលផ្តុំធនធានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដូចជា បណ្តាញ, ម៉ាស៊ីនមេ, ឧបករណ៍រក្សាផ្ទុកទិន្នន័យ, កម្មវិធីកុំព្យូទ័រ និង សេវាផ្សេងៗទៀត បញ្ចូលគ្នាតែមួយ ដើម្បីផ្តល់សេវាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរួម ដោយមាន លក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង និងចំណាយថវិកាតិចជាងការប្រើប្រាស់ធនធានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលដាច់ដោយឡែកៗពីគ្នា។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៨៥៣ ឧសក.ប្រក

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ៣០៩៤/១៣ គ.ស.ព ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូ អិលធីឌី ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូ អិលធីឌី (CAMBODIAN PETROCHEMICAL CO., LTD.) តំណាងដោយ លោកឧកញ៉ា [illegible] ហ៊ុ[illegible] សញ្ជាតិខ្មែរ អាយុ៦៣ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៨២១៧[illegible] ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានអាសយដ្ឋានបច្ចុប្បន្នៈ លេខ៦ ផ្លូវ[illegible] ក្រុមទី១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ [illegible] ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ប្រេងកាត | ១៩២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** "រោងចក្រចម្រាញ់ប្រេងកាត ខេមបូឌាន អេត្រូខេមីខល ខូ អិលធីឌី"

**ទីតាំងរោងចក្រ៖** "តំបន់សេដ្ឋកិច្ចពិសេស អេច.ខេ.ជី ភូមិព្រែកទាល់ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ"

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៧០ ឧស.ក.ក.រ.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ១១៥៤/១៤គ.រ.ក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីន ហុងយ៉ាង ហ្វើនីឈ័រ (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីន ហុងយ៉ាង ហ្វើនីឈ័រ (ខេមបូឌា) ខូ អិលធីឌី (XIN HONGYANG FURNITURE (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី SUN LIYUE សញ្ជាតិចិន អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G39866099 ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.5, Building 4, Wang He Hua Yuan, Hai Zhou Sub District, Haining City, Zhe Jiang Province, China ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| គ្រឿងសង្ហារឹម | ៣១០០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតគ្រឿងសង្ហារឹម ស៊ុន ហុងយ៉ាង ហ្វើនីឈ័រ (ខេមបូឌា) ខូ អិលធីឌី "*

**ទីតាំងរោងចក្រ៖** *" សួនឧស្សាហកម្មវឌ្ឍនៈ II ផ្លូវជាតិលេខ៣ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមមូលប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។ ៧៦៤

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៧១ ឧស.កឧ.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-យោងលិខិតលេខ ១១១១/១៣ ស.ក.ស.ព ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូឌាន យ៉ូ មី ហុង ហៅហូល ប្រដាក់ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣

## <u>សម្រេច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាន យ៉ូ មី ហុង ហៅហូល ប្រដាក់ (CAMBODIAN YO MI HONG HOUSEHOLD PRODUCTS CO., LTD.) តំណាងដោយ លោក CHEN ZHONG សញ្ជាតិចិន អាយុ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E33827506 ចុះថ្ងៃទី០[illegible] ខែ[illegible] ឆ្នាំ២០[illegible] មានអាសយដ្ឋានបច្ចុប្បន្ន៖ No 17, Dongting, Guxiang, New Cillage, Dongting Town, Xishan, Wuxi, Jiangsu, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| កម្រាលព្រំ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ | ១៣៩២ |

**ផ្លាកឈ្មោះរោងចក្រ ៖** "*រោងចក្រតម្បាញ ខេមបូឌាន យូ មី ហុង ហៅហ្វល ប្រដាក់*"

**ទីតាំងរោងចក្រ ៖** "*តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម) ស្រុកព្រៃនប់ ខេត្តព្រះសីហនុ*"

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹង ត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់ កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។ ៗ

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តព្រះសីហនុ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៨ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៩៣ ឧសក.ក.ក.ឧ.ច

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-យោងលិខិតលេខ០៩៣៥/១៣ ស.ត.ស.ព ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូត្រាក់ ខូអិលធីឌី ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣

## <u>សម្រេច</u>

<u>**ប្រការ១៖**</u> អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូត្រាក់ ខូអិលធីឌី ( CAMBOTRUCK Co., Ltd.) តំណាងដោយ លោកស្រី ZHOU CHUNFANG សញ្ជាតិចិន អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G51260108 ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ននៅ Jiangsu China ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ឧបករណ៍ដឹកជញ្ជូនតវ៉ាន់ប្រើដៃរុញ (Hand Pallet Truck) | ២៨១៦ |

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រតម្លើងគ្រឿងចក្រលើកដាក់ឥវ៉ាន់ ខេមបូគ្រាក់ ខូអិលធីឌី"*

**ទីតាំងរោងចក្រ ៖** *"តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្ពាន់ដែង ឃុំរាម) ស្រុកព្រៃនប់ ខេត្តព្រះសីហនុ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់តែកេរ្តិ៍ភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ ៗ/

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឱ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹង ត្រូវចេញឱ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់ កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។ /.

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តព្រះសីហនុ
 "ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ